# ធ

**ធ** ព្យញ្ជនៈទី ៤ ក្នុងវគ្គទី ៤ ជាទន្តជៈ ព្រោះសំឡេងកើតត្រង់ប្រទល់ធ្មេញ ។ ជាធនិត-ឃោសៈ ៖ តាមសំស្រ្កឹតនិងបាលីមានសំឡេងជា *ធ្ហ:* ។

**ធ័ក** (ម. ព. *ថក់*) ។

**ធញ្ញជាតិ** (ធ័ញ-ញៈជាត) *ន.* ជាតិស្រូវៈ ស្រូវគ្រប់ប្រភេទនិងស្រងែ, ពោតជាដើម ហៅថា *ធញ្ញជាតិ* ទាំងអស់ : *តម្លៃធញ្ញជាតិ, ដឹកនាំធញ្ញជាតិ* ។

**ធញ្ញមាស** (ធ័ញ-ញៈមាស) *ន.* (ម. ព. *លិង្គា* ឬ *លិគ្យា*) ។

**ធតរដ្ឋ** (ធៈតៈរ័ត) *ន.* (បា.; សំ. *ធ្ឫតរាស្ដ្រ*) ព្រះនាមមហារាជជាលោកបាល ១ អង្គ ដែលគ្រប់គ្រងទិសខាងកើត ជាអធិបតីលើពួកគន្ធព្វ : *ព្រះបាទធតរដ្ឋ* (ម. ព. *ចតុលោកបាល* ផង) ។

**ធន** (ធន់) *ន.* (បា. សំ.) ទ្រព្យ, សម្បត្តិ ។

**ធន់** *កិ.* ទ្រាំ, អត់ធ្មត់; ស៊ូ : *ធន់ជំងឺ, ធន់ក្តៅ, ធន់ត្រជាក់, គាត់ប្រើឲ្យធ្វើការធ្ងន់ណាស់ ខ្ញុំធន់មិនបានទេ* ។

**ធនក្កីតា** (ធៈន័ក-កីតា) *ន.* (បា.; សំ. *ធនក្រីតា*) ទាសីឬស្ត្រីដែលបុរសលោះដោយទ្រព្យយកមកធ្វើជាភរិយា ។

**ធនក្រីត** (ធៈន័ក-ក្រេត) *ន.* (សំ.; បា. *ធនក្កីត*) បុរសដែលគេលោះដោយទ្រព្យយកមកធ្វើជាអ្នកបម្រើ (ទាសៈ); បើស្ត្រីជា *ធនក្រីតា* ឬ *ធនក្កីតា* (ម. ព. *ធនក្កីតា* ផង) ។

**ធនក្ស័យ** (ធៈន័ក-ស៊័យ) *ន.* (សំ. *ធនក្សយ*; បា. *ធនក្ខយ*) ដំណើរអស់ទ្រព្យ ។

**ធនទណ្ឌ** (ធៈនៈទ័ន) *ន.* (សំ. បា.) ប្រាក់ពិន័យ ។

**ធនធាន** (ធន់–) *ន.* (បា. សំ. *ធន* "ទ្រព្យ, សម្បត្តិ" + *ធាន* "ការទ្រទ្រង់") ទ្រព្យរបស់ផ្សេងៗដែលគង់នៅ : *គេមានធនធានច្រើន* ។

**ធនប័ណ្ណ** (ធៈនៈប័ន) *ន.* (ដូចគ្នានឹង *ធនបត្រ* ដែរ) ។

**ធនបត្រ ឬ –ប័ត្រ** (ធៈន:ប័ត) *ន.* (សំ. *ធន* "ទ្រព្យ" + *បត្រ* "សន្លឹក, ស្លឹក; ក្រដាស") ពាក្យសម្ដៅហៅក្រដាសដែលប្រើជាយជាជំនួសប្រាក់ តាមបញ្ញត្តិរបស់ធនាគារគ្រប់ប្រទេសក្នុងសម័យសព្វថ្ងៃនេះ (ក្រដាសប្រាក់) ។ (គួរប្រើពាក្យនេះតាមសម័យនិយម) ។

**ធនមូល** (ធៈន:–) *ន.* (សំ. បា.) ដើមទ្រព្យ, ទ្រព្យជាដើមទុន : *ធនមូលជាប្រភពនៃឈ្មួញ* ។

**ធនលាភ** (ធៈន:លាប) *ន.* (សំ. បា.) ការបានទ្រព្យ : *ស្វែងរកធនលាភ* ។

**ធនលោភ** (ធៈន:លោប) *ន.* (សំ. បា.) សេចក្ដីលោភទ្រព្យ; សេចក្ដីជំពាក់ចិត្តនឹងទ្រព្យ ។

**ធនសារ** (ធៈន:សា) *ន.* (បា. សំ.) ទ្រព្យមានខ្លឹម, ខ្លឹមទ្រព្យ : *ប្រាក់មាសជាធនសាររបស់មនុស្ស* ។

**ធនាករ** (ធៈនា-ក) *ន.* (បា. *ធន* + *អាករ*) ទីកន្លែងកើតធនធាន គឺទីកើតវត្ថុជាគុណប្រភពនៃទ្រព្យសម្បត្តិ ដូចជាប្រេងកាតនិងលោហធាតុជាដើម : *ប្រទេសកម្ពុជាមានធនាករដែលនៅក្នុងដីទេក្ដីកដីធំ* ។

**ធនាគារ** (ធៈនាគា) *ន.* (សំ. បា.) ឃ្លាំងដាក់ទ្រព្យ, ឃ្លាំងប្រាក់ : *ផ្ញើប្រាក់ក្នុងធនាគារ* ។

**ធនាគារិក** (–រិក) *ន.* ម្ចាស់ធនាគារ, អ្នកគ្រប់គ្រងឬកាន់កាប់ធនាគារ ។ បើស្រីជា *ធនាគារិកា* ។

**ធនាធិការី** (ធៈ–ការី) *ន.* (បា.; សំ. *ធនាធិការិន៑*) អ្នករក្សាទ្រព្យ, អ្នករក្សាឃ្លាំង; អ្នកទទួលទ្រព្យសម្រាប់របស់ត្រកូល; បើស្រីហៅ *ធនាធិការិនី* ។

**ធនិត** (ធៈ–) *ន.* (បា.) ឈ្មោះព្យញ្ជនៈ ១០ តួក្នុងវគ្គទាំង ៥ គឺ *ខ ឃ, ឆ ឈ, ឋ ឍ, ថ ធ, ផ ភ* ជាអក្សរមានសំឡេងធ្ងន់ មានស្នូរអក្សរ *ហ* លាយចូលផងសំឡេង សំ. បា. ជា *ក្ហៈ, គ្ហៈ; ច្ហៈ, ជ្ហៈ; ដ្ហៈ (ឬ ដ៏្ហៈ), ឌ្ហៈ; ត្ហៈ, ទ្ហៈ; ប្ហៈ(ផ្ះ), ព្ហៈ;* ជាគូគ្នានឹងព្យញ្ជនៈជា *សិថិល* ១០ តួគឺ *កៈ, គៈ; ចៈ, ជៈ; ដៈ (ឬ ដ៏ៈ), ឌៈ; តៈ, ទៈ; បៈ* (ប៉ៈ), *ពៈ* (ខ្មែរយល់ថា *សិថិល* "មានសំឡេងធូរ", *ធនិត* "មានសំឡេងតឹង ព្រោះមានសំឡេង *ហ* ល្បំជាមួយផង; តែបើភាសាខ្មែរយើងក៏ *សិថិល* និង *ធនិត* មានសំឡេងធូរតឹងវៀងគ្នាដែរ គួរតែស្គាល់និយាយកុំឲ្យច្រឡំគ្នា, ដូចព្យញ្ជនៈជា *សិថិល* ជា *កូន, កេន,* ម្ដាយ *កេក; គា, គោគាន; ចេះ, ចៃ; តោត, តាត, តោន; ប៉ូ, ប៉ុន* ជាដើម កុំនិយាយជាសំឡេង *ធនិត* ជា *ខូន, ខេន,* ម្ដាយ *ខេក; ឃា, ឃោឃាន; ឆេះ, ឆៃ; ថោត, ថាត, ថោន; ផូ, ផុន ។ល។* ទើបច្បាស់តាមសំឡេងព្យញ្ជនៈរបស់ជាតិយើង។

**ធនិន** (ធៈ–) *គុ.* ឬ *ន.* (សំ. *ធនិន៑*) អ្នកមានទ្រព្យ, សេដ្ឋី ។



**ធនុ** (ធៈនុ) *ន.* (បា.; សំ. *ធនុ* ឬ *ធនុស៑*) ធ្នូ ។ ឈ្មោះរាសី (ខែ) ទី ៩ ប្រើតាមសុរិយគតិ មាន ៣០ ថ្ងៃ, ហៅថា *ធនុរាសី* ឬ *ខែធនុ* ត្រូវគ្នានឹងខែដេសំបបារាំងសែស ។ សព្វថ្ងៃនេះ យើងប្រើថា *ធ្នូ* ជាខែទី ១២ ។

**ធនុហត្ថ** (ធៈនុ-ហាត់) *ន.* (បា.; សំ. *ធនុហស្ត*) អ្នកមានធ្នូក្នុងដៃ គឺខ្មាន់ធ្នូ : *ពួកធនុហត្ថ* (ហៅថា *កាន់ធហត្ថ* "កាន់-ធៈហាត់" ក៏បាន) ។

**ធមនី** (ធៈមៈនី) *ន.* (បា.; សំ. *ធមនិ*) សរសៃដែលនាំសព្វជាតិគ្រាប់ក្នុងសព៌ាង្គកាយ, សរសៃឈាម (រ. ស.) : *ព្រះធមនី* (ម. ព. *ឧហា;* ៦៦) ។

**ធម្ម** (ធ័ម-មៈ) *ន.* (បា.; សំ. *ធម៌*) ធម៌, សភាវៈទ្រទ្រង់សត្វលោក គឺ បុណ្យ, បាប, សុចរិត, ទុច្ចរិត; ហេតុ; សភាព; ធម្មតា; ប្រក្រតី; ធម្មជាតិ; ប្រាជ្ញាញាណ; គុណ; សេចក្ដីចម្រើន; អារម្មណ៍ខាងផ្លូវចិត្ត; ការរំពឹង, សង្ខារ; កិរិយាអាចារៈ; បរិយត្តិ; ច្បាប់ ។ល។ ពាក្យនេះប្រើសម្រាប់រៀងភ្ជាប់ពីខាងដើមសព្ទឯទៀតដូចជា *ធម្មកថា* (ធ័ម-មៈកៈថា) *ន.* (បា.) សំដីដែលជាធម៌; ការសំដែងធម៌ ។ *ធម្មកម្ម* (ធ័ម-មៈកឹម) *ន.* (បា.) អំពើ, កិច្ចការដែលប្រកបដោយធម៌, ដែលត្រូវតាមធម៌ ។ ព. ផ្ទ. *អធម្មកម្ម* ។ *ធម្មកាយ* (ធ័ម-មៈ–) *ន.* (បា.; សំ. *ធម៌កាយ*) កាយមួយយ៉ាងក្នុងកាយទាំងបីរបស់ព្រះសព្វញ្ញុពុទ្ធគឺ *រូបកាយ, នាមកាយ, ធម្មកាយ;* ព្រះធម៌ដែលជាពុទ្ធភាសិតហៅថា *ធម្មកាយ* ព្រោះទុកដូចជារូបកាយរបស់ព្រះអង្គ សូម្បីទ្រង់បរិនិព្វានទៅហើយ ក៏នៅមានព្រះធម៌នេះជាតំណាងព្រះអង្គ ។ *ធម្មការ* (ធ័ម-មៈ–) *ន.* (បា. *ធម្ម* + *ការ*) ឈ្មោះក្រសួងរដ្ឋមន្ត្រីសម្រេចកិច្ចខាងផ្លូវសាសនា : *ក្រសួងធម្មការ* ។ *ធម្មក្ខន្ធ* (ធ័ម-ម៉ាក់-ខ័ន) *ន.* (បា.; សំ. *ធម៌ស្កន្ធ*) ពួកធម៌, កងធម៌; ចំនួនកងធម៌ជាពុទ្ធវចនៈក្នុងព្រះត្រៃបិដក ហៅថា *ព្រះធម៌ ៨ ម៉ឺន ៤ ពាន់ធម្មក្ខន្ធ* (ម. ព. *ខន្ធ* ផង) ។ *ធម្មគុណ* (ធ័ម-មៈ-គុណ) *ន.* (បា.; សំ. *ធម៌គុណ*) គុណព្រះធម៌ គឺសភាវៈដែលស្រោចស្រង់ទ្រទ្រង់សត្វអ្នកប្រតិបត្តិតាមគន្លងធម៌ឲ្យបានសេចក្ដីសុខ ។ *ធម្មគារវ* (ធ័ម-មៈ-គារ៉ាវ) *ន.* (សំ. *ធម៌* + *គៅរវ;* បា. *ធម្ម* + *គារវ*) សេចក្ដីកោតក្រែងចំពោះធម៌ គឺសេចក្ដីប្រព្រឹត្តប្រតិបត្តិតាមគន្លងធម៌ ។ ឈ្មោះសាស្ត្រាប្រែរាយមួយខ្សែ សម្រាប់សម្ដែងជាមុខបន្ទូលប្រាប់សេចក្ដីគោរពធម៌ ក្នុងកាលបុណ្យធំៗ តាមទម្លាប់ពុទ្ធសាសនិកជនក្នុងកម្ពុជរដ្ឋ : *សាស្ត្រាព្រះធម្មគារវ* ។ *ធម្មចក្ក* (ធ័ម-មៈ-ច័ក) *ន.* (បា.; សំ. *ធម៌ចក្រ*) ចក្រគឺធម៌ឬធម៌ដូចជាកង់ គឺធម៌ដែលព្រះសព្វញ្ញុពុទ្ធទ្រង់ត្រាស់សម្ដែងជាដំបូងបង្អស់ ក្នុងកាលដែលព្រះអង្គបានត្រាស់ទើបនឹងបាន ៤៩ ថ្ងៃ, ទ្រង់សម្ដែងអរិយសច្ច ៤ បង្កើតដំណើរសេចក្ដីដូចជាកង់រទេះ ។ *ធម្មចក្កប្បវត្តនសូត្រ* (ធ័ម-មៈ-ច័ក-ក័ប

ប៉ិវ៉ុត-ត:ន៉ៈសូត) ន. (បា. —សុត្ត; សំ. ធម៌ចក្រប្រវត៌នសូត្រ) ឈ្មោះសូត្រដែលព្រះសម្ពុទ្ធទ្រង់សម្ដែងធម្មចក្រ ។ ធម្មចក្ខុ (ធ័ម-ម:-ច័ក្ខុ) ន. (បា.; សំ. ធម៌ចក្សុស៑ ឬ—ចក្សុ) ភ្នែកគឺធម៌ឬធម៌ទុកដូចជាភ្នែក, បានខាងឯអរិយមគ្គជាន់ក្រោមបីប្រភេទគឺ សោតាបត្តិមគ្គ, សកទាគាមិមគ្គ, អនាគាមិមគ្គ; តែប្រើសំដៅចំពោះ សោតាបត្តិមគ្គ (ម. ព. មគ្គ និង អរិយមគ្គ ផង) ។ ធម្មចេតិយ (ធ័ម-ម:ចេតិយ៉ៈ ឬ—ចេតី) ន. (បា.; សំ. ធម៌ចៃត្យ) ចេតិយដែលបញ្ចុះព្រះធម៌ ។ គម្ពីរ, ក្បួនគម្ពីរឬក្បួនដែលចម្លងគម្ពីរ, ក្រាំង, សៀវភៅធម៌ជាពុទ្ធសាសនា, ជាសុភាសិតក៏ហៅថា ធម្មចេតិយ ដែរ (ម. ព. ចេតិយ ផង) ។ ធម្មជាត ឬ ធម្មជាតិ (ធ័ម-ម:-ជាត) ន. (បា.) ធម៌, សភាវៈ, សភាព ។ ធម្មតា (ធ័ម-ម:-តា) ន. (បា.) ប្រក្រតី, អ៊ីវដែលតែងមានមក, ទំនៀម, ទម្លាប់ ។ ធម្មទាន (ធ័ម-ម:—) ន. (បា.) ការឲ្យធម៌ គឺការសម្ដែង, និយាយ, បង្រៀនធម៌; ការកសាងគម្ពីរធីកធម៌វិន័យ : ធ្វើធម្មទាន, កសាងធម្មទាន; ធម្មទានមានផលច្រើនជាងទានទាំងពួង ព្រោះជាគ្រឿងប្រាប់ផ្លូវទៅសុគតិ ។ ធម្មទូត (ធ័ម-ម:—) ន. (បា.) ទូតរបស់ធម៌គឺអ្នកដែលគេបញ្ជូនទៅកាន់ទីផ្សេងៗ ដើម្បីផ្សព្វផ្សាយធម៌ ។ ធម្មទេសនា (ធ័ម-ម:-ទេសៈន៉ា ឬ—ទេស្នា) ន. (បា.) ការ, ដំណើរសម្ដែងធម៌ ។ ធម្មធាតុ (ធ័ម-ម:-ធាត) ន. (បា.) អ្នកមានធាតុជាធម៌ គឺព្រះពុទ្ធ; ធាតុគឺធម៌ ។ ធម្មនិទ្ទេស (ធ័ម-ម:-និទ-ទេស) ន. (បា.) និទ្ទេសនៃធម៌, ការសម្ដែងញែកចែកនូវធម៌ ។ ធម្មនិយម ឬ ធម្មនិយាម (ធ័ម-ម:-និយ៉ំ ឬ—និយាម) ន. (បា.) សេចក្ដីកំណត់តាមធម្មតា, អ៊ីវៗដែលរមែងកើតមានតាមធម្មតា ។ ធម្មនីតិ (ធ័ម-ម:—) ន. (បា.) ឈ្មោះគម្ពីរមួយដែលសម្ដែងអំពីរបៀបនីតិលោក និងនីតិធម៌ ។ ធម្មនុញ្ញ ឬ ធម្មនុញ្ញ (ធ័ម-ម:-នុញ, ឬ—នុញ) ន. (បា.) ឈ្មោះច្បាប់មួយក្រម សម្ដែងពីរបៀបការក្នុងតុលាការ (ម. ព. រដ្ឋធម្មនុញ្ញ ផង) ។ ធម្មន្តេវាសិក (ធ័ម-ម័ន-តេវាសិក) ន. (បា.) សិស្សព្រោះធម៌ គឺអ្នកសិក្សាធម៌អាចអំពីសំណាក់គ្រូអាចារ្យណាមួយ ។ ធម្មប្បដិបត្តិ (ធ័ម-ម័ប-ប៉ៈ-ដិ-ប៉ុត-តិ ឬ—ប៉ៈដិបាត់) ន. (បា.) ការប្រតិបត្តិធម៌, ការប្រព្រឹត្តតាមច្បាប់ : ព្រះពុទ្ធទ្រង់លើកយកធម្មប្បដិបត្តិមកជាគោលធំបំផុត ។ ធម្មប្បដិរូប (ធ័ម-ម័ប-ប៉ៈដិ—) ន. (បា.) ការប្រៀបប្រដូចស្រដៀងនឹងធម៌, ធម៌ប្លម, ធម៌ក្លែងក្លាយ : សេចក្ដីត្រង់ហ្នឹងនេះ គឺជាធម្មប្បដិរូបទេ ។ ធម្មប្បវិសម្ភិត (ធ័ម-ម័ប-ប៉ៈវិ ស័ក-ភិត) ន.



(បា.) ការចែកប្រាជ្ញាយល់នូវធម៌ក្នុងធម៌, ប្រាជ្ញាចែកភ្លឺស្វាងផុតទើសទាក់ក្នុងធម៌ ។ ធម្មបថ (ធ័ម-ម:-បត់) ន. (បា.) គន្លងធម៌, ផ្លូវធម៌ ។ ធម្មបទ (ធ័ម-ម:-បត់) ន. (បា.) ផ្លូវធម៌, ពាក្យធម៌ ។ ឈ្មោះគម្ពីរព្រះពុទ្ធសាសនាក្នុងសុត្តន្តបិដកខាងខុទ្ទកនិកាយ ហៅថា ខុទ្ទកនិកាយ ធម្មបទ, ជាពុទ្ធភាសិតសុទ្ធតែជាគាថាទាំងអស់ ហៅថា ធម្មបទគាថា ឬ គាថាធម្មបទ ។ ធម្មបទដ្ឋកថា (ធ័ម-ម:-ប៉ៈទ័ត-ឋ:កៈថា) ន. (បា.) ឈ្មោះអដ្ឋកថា គឺគម្ពីរអធិប្បាយសេចក្ដីគាថាធម្មបទ, អដ្ឋកថានេះមានពីរភាគ, ភាគខាងដើមហៅថា ធម្មបទដ្ឋកថាបុព្វភាគ, ភាគខាងចុងហៅថា ធម្មបទដ្ឋកថាបច្ឆិមភាគ ។ ធម្មបរិយាយ (ធ័ម-ម:-ប៉ៈរិយ៉ាយ ឬ—បរិ—) ន. (បា.) បរិយាយនៃធម៌, សេចក្ដីអធិប្បាយញែកញ៉ែកនូវធម៌, ការពន្យល់សេចក្ដីតាមដំណើរធម៌ : ធម្មបរិយាយនេះមិនត្រូវតាមរបៀបទេ, ធម្មបរិយាយនោះពីរោះគួរជាទីជ្រះថ្លាណាស់ ។ ធម្មប្បមោទ្យ (ធ័ម-ម:បាំមោត) ន. (បា. ធម្មប្បមោជ្ជ; សំ. ធម៌ប្រមោទ ឬ ធម៌ប្រាមោទ្យ) សេចក្ដីរីករាយចំពោះធម៌ ។ ធម្មបាល (ធ័ម-ម:—) ន. (បា.) អ្នករក្សាធម៌ ។ ធម្មបីតិ (ធ័ម-ម:-ប៉ីតិ) ន. (បា. ធម្មបីតិ; សំ. ធម៌ប្រីតិ) ដំណើរប្រេមឆ្អែតនូវធម៌; សេចក្ដីរីករាយចំពោះធម៌ : អ្នកមានធម្មបីតិក្នុងសន្ដាន រមែងសម្រេចឥរិយាបថទាំង៤ជាសុខ ។ ធម្មបូជា (ធ័ម-ម:—) ន. (បា.) បូជាចំពោះធម៌, បូជាចំពោះអ្នកចេះធម៌ឬចំពោះអ្នកប្រព្រឹត្តធម៌ : វត្ថុនេះជាធម្មបូជារបស់ខ្ញុំ ។ ធម្មមន្ទីរ (ធ័ម-ម:-ម៉ន់ទី) ន. (បា. ធម្មមន្ទិរ) ផ្ទះ, កន្លែងតម្កល់ធម៌ គឺបណ្ណាល័យតម្កល់គម្ពីរផ្សេងៗ ។ ធម្មមាមក: (ធ័ម-ម:-មាម៉:ក:) ន. (បា. ធម្មមាមក) អ្នកដែលរាប់អានគោរពថាព្រះធម៌ជារបស់អាត្មាអញ គឺអ្នកដែលជឿធម៌ជាពុទ្ធសាសនាស៊ប់ចិត្ត ឥតមានងាកបែរ ។ ធម្មមូល (ធ័ម-ម:—) ន. (បា.) ឫសគល់នៃធម៌, ទីតាំងនៃធម៌ : សេចក្ដីដឹងគុណនិងការតបគុណអ្នកមានគុណ ជាធម្មមូល ។ ធម្មមោទនា (ធ័ម-ម:មោទ:នា) ន. (បា.) សេចក្ដីរីករាយចំពោះធម៌ ។ ធម្មយុត្ត (ធ័ម-ម:យុត) ន. ឬ គុ. (បា.; សំ. ធម៌យុក្ត) អ្នកប្រកបដោយធម៌; ដែលប្រកបដោយធម៌ ។ ធម្មយុត្តិកនិកាយ (ធ័ម-ម:-យុត-តិក:—) ន. (បា.) ឈ្មោះគណៈបព្វជិតក្នុងព្រះពុទ្ធសាសនាសម័យសព្វថ្ងៃនេះ ដែលជាគូគ្នានឹងមហានិកាយ (ម. ព. នេះផង) ។ ធម្មរក្ខិត (ធ័ម-ម:-រ័កខិត) ន. ឬ គុ. (បា.; សំ. ធម៌រក្សិត) អ្នករក្សាធម៌ ។ ពាក្យនេះច្រើនប្រើជាឈ្មោះភិក្ខុឬសាមណេរក្នុងព្រះពុទ្ធសាសនា ។ ខ្លះកាលប្រើជាសមណស័ក្តិទំនងជាគណៈក៏មាន ។ ធម្មរក្ខិតា (ធ័ម-ម:-រ័កខិតា) ន. (បា.) ស្ត្រីដែលជាអ្នកប្រព្រឹត្តធម៌ត្រូវជា ព្រះ-

ត្រូវរក្សាជាធំក្នុងលោកនេះ : *ស្រីធម្មរក្ខិតា* ។ *ធម្មរក្សា* (ធ័ម-ម៉ៈ-រ័កសា) ន. (សំ. *ធម៌ + រក្ស*) ការរក្សាធម៌ ។ ពាក្យនេះសព្វថ្ងៃ ខ្មែរយើងប្រើជាងារមន្ត្រីក្នុងក្រុមសង្ឃការី : *ព្រះធម្មរក្សា* ។ *ធម្មរតនៈ* ឬ *ធម្មរ័តន៍* (ធ័ម-ម៉ៈ-រៈតៈន៉ៈ ឬ –រ័ត) ន. (បា. *ធម្មរតន*; សំ. *ធម៌រត្ន*) កែវគឺព្រះធម៌ ឬព្រះធម៌ដែលទុកជាកែវដ៏វិសេស ។ *ធម៌រត្ន* ឬ *ធម៌រ័ត្ន* (ធ័រ-រ័ត) ន. (ដូចគ្នានឹង *ធម្មរតនៈ* ឬ *ធម្មរ័តន៍*) ។ *ធម្មរាជ* (ធ័ម-ម៉ៈ-រាច) ន. (បា.) លោកដែលជាស្ដេចព្រោះត្រាស់ដឹងធម៌ (ព្រះសព្វញ្ញុ) : *ព្រះសម្ពុទ្ធជាធម្មរាជ* ។ *ធម្មលាភ* (ធ័ម-ម៉ៈ-លាប) ន. (បា. *ធម្ម + លាភ*) លាភដែលកើតដោយធម៌, ការបានទ្រព្យដោយផ្លូវធម៌ : *ទ្រព្យនេះជាធម្មលាភរបស់ខ្ញុំ* ។ *ធម្មលិខិត* (ធ័ម-ម៉ៈ–) ន. (បា. *ធម្ម+លិខិត*) អក្សរសរសេរ, កំណត់ត្រា, ចម្លងធម៌ ។ ពាក្យនេះខ្មែរយើងប្រើជាសមណស័ក្តិរាជាគណៈជាន់ខ្ពស់ : *ព្រះធម្មលិខិត*; ក្នុងកាលព្រះករុណាជាម្ចាស់ជីវិតទ្រង់ប្រោសព្រះរាជទានតាំងដល់ទីសម្ដេចក៏មាន : *សម្ដេចព្រះធម្មលិខិត* ។ *ធម្មវិធី* (ធ័ម-ម៉ៈ–) ន. (បា.) បែបផែនតែធម៌, វិធីប្រតិបត្តិធម៌ ។ *ធម្មសង្គាយនា* (ម. ក. *ធម្មសង្គីតិ*) ។ *ធម្មសង្គាហកត្ថេរ* (ធ័ម-ម៉ៈ-សង់គាហៈក័ត-ថេរ៉ៈ ឬ –ថេ) ន. (បា.) ពួកព្រះថេរៈអ្នកសង្គាយនាធម៌ គឺពួកព្រះថេរានុត្ថេរៈ ដែលប្រជុំគ្នាផ្ទៀងព្រះត្រៃបិដក ដូចកាលប្រជុំធ្វើបឋមសង្គាយនាជាដើម ។ *ធម្មសង្គីតិ* (ធ័ម-ម៉ៈ-សង់គីតិ) ន. (បា.) ការប្រជុំផ្ទៀងធម៌គឺការផ្ទៀងផ្ទាត់ប្រមូលធម្មវិន័យឲ្យមានរបៀបត្រឹមត្រូវតាមបែបដើម (ហៅថា *ធម្មសង្គាយនា* ក៏បាន) ។ *ធម្មសង្គីតិ-កាចារ្យ* (ធ័ម-ម៉ៈ-សង់គីតិកាចា) ន. (បា. សំ.; បា. *ធម្មសង្គីតិកាចរិយ*) ពួកលោកអាចារ្យអ្នកផ្ទៀងផ្ទាត់ប្រមូលធម៌ (ពាក្យនេះជាវេវចនៈនៃ *ធម្មសង្គាហកត្ថេរ*) ។ *ធម្មសភា* (ធ័ម-ម៉ៈ-សៈភា) ន. (បា.; សំ. *ធម៌សភា*) សាលាសម្រាប់ប្រជុំប្រឹក្សាអំពីធម៌ ។ សាលាយុត្តិធម៌; សាលាជំនុំជម្រះក្ដី ។ *ធម្មស្សវនកាល* (ធ័ម-ម័ស-សៈវៈន៉ៈ–) ន. (បា.; សំ. *ធម៌-ស្រវណកាល*) កាល, ពេលដែលសាធុជនគួរស្ដាប់ធម៌ (ថ្ងៃសីលឬក្រៅពីថ្ងៃសីលក៏ដោយ ដែលមានពេលទំនេរសម្រាប់សាធុជនស្ដាប់ធម៌ ហៅថា *ធម្មស្សវនកាល*) ។ *ធម្មសាកច្ឆា* (ធ័ម-ម៉ៈ-សាក័ច-ឆា) ន. (បា.) ការសន្ទនាអំពីធម៌, ការប្រឹក្សា, សាកសួរអំពីធម៌ : *ធ្វើធម្មសាកច្ឆា*, *ស្ដាប់ធម្មសាកច្ឆា* ។ *ធម្មសាត្រ* (ធ័ម-ម៉ៈ-សាត) ន. (ម. ក. *ធម្មសាស្ត្រ*) ។ *ធម្មសាមី* (ធ័ម-ម៉ៈ-សាមី) ន. (បា. *ធម្មស្សាមី*; សំ. *ធម៌ស្វាមិន៑*) ម្ចាស់លើគេព្រោះបានត្រាស់ដឹងធម៌ (ព្រះសព្វញ្ញុ) : *ព្រះធម្មសាមី*; *ព្រះសម្មាសម្ពុទ្ធទ្រង់ជាធម្មសាមី* ។ *ធម្មសារ* (ធ័ម-ម៉ៈ–) ន. (បា.) ខ្លឹមធម៌, ធម៌មានខ្លឹម គឺធម៌ដែលនាំអ្នកប្រព្រឹត្តឲ្យរួចចាកទុក្ខ ។ *ធម្មសាលា* (ធ័ម-ម៉ៈ-សាល៉ា) ន. (បា.; សំ. *ធម៌សាលា*) សាលាសម្រាប់សាធុជនប្រជុំស្ដាប់ធម៌, ប្រឹក្សាអំពីធម៌; សាលាសម្រាប់ប្រជុំរៀនធម៌ (រោងរៀនធម៌) ។ *ធម្មសាសន៍* (ធ័ម-ម៉ៈ-សាស) ន. (បា.) ពាក្យប្រដៅប្រកបដោយធម៌, ពាក្យបង្គាប់ឬបទដែលចាត់ចែងដោយច្បាប់ ។ *ធម្មសាស្ត្រ* (ធ័ម-ម៉ៈ-សាស) ន. (បា. សំ.; សំ. *ធម្មសាស្ត្រ*; បា. *ធម្មសត្ថ*) ឈ្មោះគម្ពីរសំដែងអំពីយុត្តិធម៌ (ខាងតុលាការ) : *គម្ពីរធម្មសាស្ត្រ* ។ ឈ្មោះក្រមច្បាប់យុត្តិធម៌ (ខាងតុលាការ) : *ច្បាប់ធម្មសាស្ត្រ* (ហៅក្លាយជា *ធម្មសាត្រ* ក៏មាន, គួរប្រើ *ធម្មសាស្ត្រ* ឬ *ធម៌សាស្ត្រ* វិញ ត្រឹមត្រូវតាមប្រកតិនៃពាក្យ) ។ *ធម្មសេនាបតី* (ធ័ម-ម៉ៈ-សេន៉ាប៉ៈដី) ន. (បា. *ធម្មសេនាបតិ*) នាមវិសេសរបស់ព្រះសារីបុត្តត្ថេរជាអគ្គសាវក (សាវកខាងស្ដាំ) នៃព្រះសក្យមុនីសម្ពុទ្ធ; មានន័យមួយផ្សេងថា ព្រះថេរៈណាស្រេចតាំងអស់ក៏សុទ្ធតែហៅតាមវិសេសថា *ធម្មសេនាបតី* បានដែរ ព្រោះលោកច្បាំងឈ្នះសេនាគឺអកុសលធម៌ ដោយកម្លាំងទ័ពគឺកុសលធម៌ផ្សេងៗគ្នាទាំងអស់; ប៉ុន្តែពាក្យនេះ ដែលប្រើប្រាកដ ចំពោះតែជានាមវិសេសរបស់ព្រះសារីបុត្តត្ថេរប៉ុណ្ណោះ : *ព្រះសារីបុត្តជាធម្មសេនាបតី*, *ព្រះធម្មសេនាបតី* ។ *ធម្មសំវេគ* (ធ័ម-ម៉ៈ-សង្វេក ឬ ធ័ម-ម៉ៈ-សង្វែក) ន. (បា.) សេចក្ដីសង្វេគចំពោះធម៌មាន ទុក្ខ អនិច្ចំ អនត្តា ជាដើម (ម. ក. *សង្វេគ*) ។ *ធម្មាចារ្យ* (ធ័ម-មាចា) ន. (សំ. *ធម៌ាចាយ៌*; បា. *ធម្មាចរិយ*) អាចារ្យអ្នកបង្រៀនធម៌, គ្រូព្រះធម៌ : *លោកជាធម្មាចារ្យរបស់ខ្ញុំ* ។ *ធម្មាធិករណ៍* (ធ័ម-មា-ធិ-ក) ន. (បា. *ធម្មាធិករណ*; សំ. *ធម៌ាធិករណ*) អធិករណ៍អំពីធម៌; សាលាយុត្តិធម៌, សាលាជំនុំក្ដី ។ *ធម្មាធិការ* (ធ័ម-មា–) ន. (បា.; សំ. *ធម៌ាធិការ*) ដូចគ្នានឹង *ធម្មាធិករណ៍* ដែរ ។ *ធម្មាធិការនាយក* (ធ័ម-មាធិការ៉ៈនាយក់) ន. (បា.; សំ. *ធម៌ាធិ–*) នាយក (អធិបតីឬចាងហ្វាង) សាលាជំនុំក្ដី ។ *ធម្មាធិការី* (ធ័ម-មាធិការី) ន. (បា.; សំ. *ធម៌ាធិការិន៑*) អ្នកពិភាក្សាក្ដី, ភ្នាក់ជំនុំក្ដី (ចៅក្រម) ។ *ធម្មាធិដ្ឋាន* (–ធិត-ឋាន) ន. (បា.) ការតាំងចិត្តចំពោះធម៌; ការលើកយកធម៌ឬយកច្បាប់មកជាទីតាំង, ពាក្យឬប្រយោគដែលនិយាយសំដៅចំពោះអំពើឬចំពោះធម៌ត្រង់តែម្យ៉ាង មិនបាននិយាយដល់រូបបុគ្គលអ្នកធ្វើអ្នកប្រព្រឹត្ត ដូចជាប្រយោគថា : *ចុះរមែងឲ្យផលអាក្រក់*, *បុណ្យរមែងឲ្យផលល្អ* យ៉ាងនេះជាដើម

ហៅជាពាក្យថា ធម្មាធិដ្ឋាន ។ ព. ផ្ទ. បុគ្គលាធិដ្ឋាន (ម. ព. នោះផង) ។ ធម្មាធិបតេយ្យ (ធ័ម-មាធិប៉ៈតៃ) ន. ឬ គុ. (បា.) អ្នកដែលមានធម៌ជាអធិបតី គឺអ្នកដែលធ្វើអ្វីៗ អាងអស់ធម៌និងច្បាប់ជាធំ; ដំណើរដែលអាងអស់ធម៌និងច្បាប់ជាធំ ។ ធម្មាធិប្បាយ (ធ័ម-មាធិប-បាយ) ន. (បា.) សេចក្ដីអធិប្បាយធម៌, ដំណើរពន្យល់ធម៌ ។ ធម្មានុរូប គុ. (បា. ធម្ម + អនុរូប) ដែលសមគួរ, ដែលមានទំនងដ៏សមគួរតាមធម៌, ដែលស្របទៅតាមធម៌, ដែលសមល្មមត្រឹមត្រូវតាមច្បាប់ ។ ធម្មារម្មណ៍ (—រ៉ម) ន. (បា.) អារម្មណ៍របស់ចិត្ត; អារម្មណ៍គឺធម៌ ឬធម៌ជាអារម្មណ៍ ។ ក្នុងអភិធម្មសង្គហៈថា ធម៌ ៦ យ៉ាងគឺ បសាទរូប ១ សុខុមរូប ១ ចិត្ត ១ ចេតសិក ១ រូប ១ និព្វាន ១ ហៅថា ធម្មារម្មណ៍ ។ ធម្មាសនៈ ឬ ធម្មាសន៍ (ធ័ម-មាសៈន៉ៈ ឬ ធ័ម-មាស) ន. (បា. ធម្មាសន) អាសនៈសម្រាប់គង់សម្ដែងធម៌ ឬសម្រាប់គង់សូត្រធម៌, គ្រែសម្រាប់គង់សម្ដែងធម៌: គង់លើធម្មាសនៈ; គ្រែធម្មាសន៍ ។ ធម្មិក (ធ័ម-មិក) គុ. (បា.; សំ. ធាម៌ិក) ដែលប្រកបដោយធម៌ : ព្រះបាទធម្មិក, មនុស្សធម្មិក, ទ្រព្យធម្មិក, ភោជនធម្មិក ។ល។ ធម្មិកកថា (ធ័ម-មិកៈកថា) ន. (បា.; សំ. ធាម៌ិកកថា) ស្នេហ៍ប្រកបដោយធម៌, ស្នេហ៍ប្រទានសតិធម៌ : ព្រះមហាក្សត្រត្រាស់ ទ្រង់ជាធម្មិកកថា ។ ធម្មុទ្ទេស (ធ័ម-មុត-ទេស) ន. (បា.) ការលើកយកចំនួនមាតិកាធម៌មួយៗមកសម្ដែងប្រាប់ឲ្យដឹងថា ប៉ុណ្ណេះប៉ុណ្ណោះ: ធម្មកថិកមុននឹងអធិប្បាយពន្យល់ធម៌ណាមួយ តែងសម្ដែងនូវធម្មុទ្ទេសសិន ។ មួយទៀតថា ការលើកយកធម៌ ៤ យ៉ាងមកពីបាលីណាឬយកមកសម្ដែងតាមករណ៍ពិត ហៅថា ធម្មុទ្ទេស, ធម៌ ៤ យ៉ាងនោះគឺ ១- សត្វលោក សុទ្ធតែមិនទៀងតាំងបិតថេរចិរកាលទេ តែងតែព័ទ្ធក្នុងអំណាចនៃជរា-ព្យាធិ-មរណៈ គេចមិនផុតឡើយ; ២- សត្វលោកឥតមានត្រង់ត្រាគួរឲ្យប្រសិទ្ធិការពិតពិតទេ; ៣- សត្វលោកឥតមានទ្រព្យសម្បត្តិអ្វីក្រៅពីកុសលកម្មដែលខ្លួនបានសាងសល់ទេ ព្រោះតែលះសម្បត្តិទាំងអស់ ហើយចេញចាកលោកនេះទៅ; ៤- សត្វលោកជាទាសៈនៃតណ្ហា តែងតែមានការខ្វះខាតជានិច្ច មិនដែលឆ្អែតចំណង់ខ្លួនទេ ។ល។

ធម្ម–, ធម្មា–, ធម្មិ–, ធម្មុ– (មើលក្នុងពាក្យ ធម្ម) ។

ធម្មកថិក (ធ័ម-មៈកៈថិក) ន. (បា.; សំ. ធម៌កថិក) អ្នកសំដែងធម៌ ។ ខ្មែរប្រើពាក្យនេះជាងារនៃភិក្ខុអ្នកចេះសំដែងធម៌ ភ្ជាប់ជាឋានានុក្រម ជាសហការីនៃព្រះរាជាគណៈ ជាចៅអធិការវត្តធំៗក្នុងព្រះរាជធានី ឬជាសហការីនៃមេគណ កាលបើត្រូវការឲ្យមាន : ព្រះធម្មកថិក សហការីនៃ... (ម. ព. ធម្មធរ និង វិន័យធរ ទៀតផង) ។



ធម្មធរ (ធ័ម-មៈ-ធ) ន. (បា.; សំ. ធម៌ធរ) អ្នកទ្រទ្រង់ធម៌, អ្នកកាន់ធម៌, អ្នកប្រតិបត្តិត្រឹមត្រូវតាមគន្លងធម៌ ។ ហេតុនោះ គឺងារនៃភិក្ខុក្នុងព្រះពុទ្ធសាសនា ចំពោះភិក្ខុអ្នកចេះចាំធម៌ពុំស្វះស្វែងទាល់ ។ ខ្មែរយកពាក្យនេះមកប្រើជាងារនៃភិក្ខុភ្ជាប់ជាឋានានុក្រមថា ព្រះធម្មធរ ជាគូគ្នានឹង ព្រះវិន័យធរ ជាសហការីរបស់ព្រះរាជាគណៈ ជាចៅអធិការវត្តធំៗក្នុងព្រះរាជធានី; ក្នុងសម័យបច្ចុប្បន្ន មេគណនិងអនុគណគ្រប់ខេត្ត-ស្រុក ក៏មាន ព្រះធម្មធរ ជាសហការីដែរ ហៅថា ព្រះធម្មធរ ជាសហការីនៃមេគណឬនៃអនុគណ; ដោយការដូច្នោះថា ព្រះវិន័យធរ ខាងវិន័យ, ព្រះធម្មធរ ខាងធម៌ (ម. ព. ធម្មកថិក និង វិន័យធរ ទៀតផង) ។

ធរណិន្ទ (ធៈរៈនិន) ន. (បា.; សំ. ធរណីន្ទ្រ) អ្នកដែលជាធំលើផែនដី (ស្ដេចគ្រប់គ្រងនគរ) ។ (ច្រើនតែប្រើក្នុងកាព្យ): ព្រះបាទធរណិន្ទ មានពហុទ័យជិន-ណាយ ក្ដីកិច្ចការ ទ្រង់ត្រាស់ឲ្យហៅ ព្រាហ្មណ៍ព្រឹទ្ធា-ចារ្យ និងកជបរិវារ មកគាល់ព្រះអង្គ ។

ធរណី ១ (ធៈរៈនី) ន. (សំ. បា.) ផែនដី : រកស៊ីកកាយធរណី, ព្រះធរណី ។ នាងធរណី គឺនាងគង្ហីងព្រះធរណី ។

ធរណី ២ (ធៈរៈនី) ន. បង្គោលមួយគូដែលដាំចំប្រហោងវែកចាប់ឈ្នួរទន្ទឹមគ្នាសម្រាប់ភាប់ស្នៀត ដាប់ស៊ីរឲ្យស្អាប់សាប់ ។

ធរណីផងគោម (ធៈរៈនី—) ន. បង្គោលមួយគូមានរន្ធឬចីម្ដាដែលដាំបញ្ឈរទន្ទឹមគ្នា សម្រាប់សិកស្នូលកោះភ្ជាប់នឹងគោមឲ្យមាំ ។

ធរណីផងទង់ (ធៈរៈនី—) ន. បង្គោលមួយគូមានសណ្ឋានដូចគ្នានឹងធរណីផងគោមដែរ សម្រាប់កោះភ្ជាប់ផងទង់ឲ្យមាំ ។

ធរណីទ្វារ (ធៈរៈនី—) ន. ឈើទទឹងទ្វារដែលដាក់ភ្ជាប់នឹងផែនដីឬនឹងថ្នាលខាងក្រោម ។

ធរណីសង្ឃ (ធៈរៈនីសង) ន. ទីដីរបស់សង្ឃ គឺទីដីដែលទាយកឬទាយិកាបរិច្ចាគដាក់ជាទីដីសម្រាប់វត្ត ទោះដីនោះទៅស្រែឬជាចម្ការក្ដី ទីដីនេះរាប់បញ្ចូលជាគរុភណ្ឌរបស់វត្ត... (ត. វ. ក.) ។

ធរមាន (ធៈរៈមាន) គុ. (បា.; សំ. ធរមាណ) ដែលកំពុងទ្រទ្រង់នៅ, ដែលមានជីវិតរស់នៅ : កាលព្រះសម្មាសម្ពុទ្ធទ្រង់ធរមាននៅឡើយ ... ។

ធរមានបញ្ញត្តិ (ធៈរៈមានប៉័ញ-ញ៉ាត់) ន. (បា. ធរមាន + បញ្ញត្តិ) បញ្ញត្តិដែលកំពុងមាននៅ, ច្បាប់ដែលនៅកំពុងប្រតិបត្តិតាម, បទបញ្ញត្តិដែលរាជការដាក់ឲ្យប្រតិបត្តិតាមពុំទាន់លើកលែងចោល: តបប្រតិបត្តិតាមធរមានបញ្ញត្តិ ។

ធម៌ (ធ៌) ន. (សំ.; បា. ធម្ម) សភាវៈដែលទ្រទ្រង់សត្វលោក គឺ បុណ្យ, បាប, សុចរិត, ទុច្ចរិត ។ល។ (ម. ព. ធម្ម ផង) ។ ពាក្យនេះ ខ្មែរយើងធ្លាប់ប្រើជាមធ្យមធាតុ គឺសំដៅ

យកពាក្យកេរ្តិ៍របស់ព្រះពុទ្ធ និងអត្ថបទទូទៅដែលទាក់ទងដោយពុទ្ធសាសនា : *រៀនធម៌, សូត្រធម៌, ទេសធម៌, ចាំធម៌, ស្ដាប់ធម៌, សម្ដែងធម៌, ធម៌ការ* អត្ថបទរបស់ធម៌ ។ល។

**ធាក់ ឬ ធ័ក** *កិ.* (បា. *ធក*; សំ. *ធក្ក* "បៀតបៀន; ប្រហារ; ទម្លាយ") លាតជើងលាស់ឲ្យទៅមុខ ឲ្យត្រូវនឹងបាតជើង : *ធាក់មួយជើង* ។

**ធាង** *ន.* មែកឈើខ្លះៗដែលធំវែងមានប្រធាប : *ធាងដូង, ធាងត្នោត, ធាងចេក* ។

**ធាត់** *គុ.* ទំនើសស្ដូក មិនមានសាច់ច្រើន : *មនុស្សធាត់, ក្របីធាត់* ។

**ធាតុ** (ធាត) *ន.* (សំ. បា. "សភាវៈឬវត្ថុជាតិទ្រទ្រង់ខ្លួនឯង,...") ដី, ទឹក, ភ្លើង, ខ្យល់, អាកាស : *ធាតុដី, ធាតុទឹក ។ល។* អាការៈក្នុងខ្លួន ដូចយ៉ាង សក់, ធ្មេញ, សាច់, ឈាម ជាដើម ក៏ហៅថា *ធាតុ* ។ មាស, ប្រាក់, ដែក ។ល។ ក៏ហៅថា *ធាតុ* ។ ឆ្អឹងរបស់បុគ្គលដែលគេបូជាហើយ ក៏ហៅថា *ធាតុ* ឬហៅ អដ្ឋិធាតុ ។ មូលដើមរបស់ពាក្យភាសា មានភាសាសំស្ក្រឹត, បាលីជាដើម ក៏ហៅថា *ធាតុ*, ដូចយ៉ាង *ធរណី* "ផែនដី" មកពី *ធរ*-ធាតុ "ទ្រទ្រង់"; *កម្ម* "អំពើ" មកពី *ករ*-ធាតុ "ធ្វើ" ។ល។ ប្រើរៀងភ្ជាប់ពីខាងដើមសព្ទដទៃ ត. ប. ធា-តុ ដូចជា *ធាតុកថា* (ធា-តុកៈថា) *ន.* (សំ. បា.) ឈ្មោះគម្ពីរព្រះអភិធម្មដែលសម្ដែងអំពីធាតុផ្សេងៗ ។ *ធាតុចេតិយ* (—ចេតិយៈ ឬ —ចៃឌី) *ន.* (បា.) ចេតិយដែលបញ្ចុះធាតុ, តាមសេចក្ដីក្នុងគម្ពីរព្រះពុទ្ធសាសនា សំដៅចំពោះតែចេតិយដែលបញ្ចុះព្រះសារីរិកធាតុព្រះសព្វញ្ញុពុទ្ធ ឬដែលបញ្ចុះធាតុព្រះអរហន្ត; មានន័យផ្សេងទៀតថា ទោះបីចេតិយដែលបញ្ចុះព្រះពុទ្ធរូបបាក់បែកក៏ហៅថា *ធាតុចេតិយ* ដែរ (ម. ព. *ចេតិយ* ផង) ។ *ធាតុនិធាន* *ន.* (បា.) ការតម្កល់, ការបញ្ចុះធាតុ, បុណ្យបញ្ចុះធាតុ ។ *ធាតុប្បច្ចវេក្ខណៈ* (ធាតុប-ប៉ុច-ចៈវេក-ខៈណៈ) *ន.* (បា.—ណ) ការពិចារណានូវបច្ច័យ ៤ មានចីវរប្បច្ច័យជាដើម ឲ្យឃើញថាគ្រាន់តែជាធាតុ ៤ ប៉ុណ្ណោះ : *ធាតុប្បច្ចវេក្ខណៈ ជាករណីយកិច្ចរបស់បព្វជិត* (ត. ពុ.) ។ *ធាតុវិជ្ជា* ឬ *ធាតុវិទ្យា* *ន.* (បា. *ធាតុ + វិជ្ជា*; សំ. *ធាតុ + វិទ្យា*) ចំណេះខាងការប្រកបឬផ្សំធាតុគ្រប់យ៉ាងឲ្យកើតជាធាតុថ្មីមួយឡើង ឬឲ្យប្រើការផ្សេងៗ បាន ។ *ធាតុវិការ* (—វិកា) *ន.* (សំ. បា.) ការប្រែប្រួលនៃធាតុ ។ *ធាតុអន្តរធាន* (—អន់-តៈរ៉ៈធាន ឬ —អន់-ត—) *ន.* (បា.) ការសាបសូន្យឬបាត់បង់នៃព្រះធាតុរបស់ព្រះសម្មាសម្ពុទ្ធ ។ មានសេចក្ដីតំណាលថា កាលណាសាសនារបស់ព្រះពុទ្ធគោតមនេះ បាត់សូន្យទៅ ដោយហេតុមនុស្សលោកលែងអស់សេចក្ដីគោរពហើយ, កាលនោះព្រះសារីរិកធាតុរបស់ព្រះអង្គ ទោះបីប្រតិស្ឋាននៅក្នុងទីណាក៏ដោយ សុទ្ធសឹងតែរណ្ដោតត្រសែងឯកវមកប្រជុំគ្នាទាំងអស់នៅត្រង់ពោធិព្រឹក្ស ពីកន្លែងដែលព្រះអង្គត្រាស់ដឹង



ជាដំបូង ហើយគេថាធាតុបណ្ដាលឡើងឯងនេះឆេះប្រល័យព្រះសារីរិកធាតុទាំងអស់នោះ សុសសោះសូន្យអស់ទៅ ឥតមានសេសសល់ឡើយ, ត្រង់នេះឯងហើយហៅថា *ធាតុអន្តរធាន*; ហៅម្យ៉ាងទៀតថា *ធាតុបរិនិព្វាន* ក៏បាន (តាមមនោរថបូរណីអដ្ឋកថា) ។

**ធាតុ** —(មើលក្នុងពាក្យ *ធាតុ*) ។

**ធាត្រី** *ន.* (សំ. *ធាត្រី* ឬ *ធាត្រេយី*; បា. *ធាតី* "ស្រីអ្នកទ្រទ្រង់, អ្នកថែរក្សាកូនក្មេង") មេដោះ, ស្រីជាបងក្សា ។

**ធាន** *ឬ.* ពាក្យសម្រាប់និយាយផ្សំនឹងពាក្យ *ធន* : *ធនធាន* (ម. ព. នោះ) ។

**ធានា** *ន.* (សំ. បា. *ធានា* "ដំណើរទ្រទ្រង់...") ដំណើរទទួលអះអាង, ទទួលកំរៀងលើខ្លួន ។ ប្រើតាមទម្លាប់ជា *កិ.* ឬ *ន.* ក៏បាន : *ដំណើរនេះកុំឲ្យអ្នកព្រួយ ខ្ញុំធានាជូនអ្នក ; បានខ្ញុំហ៊ានឲ្យព្រោះមានធានារ៉ាប់រង; អ្នកណាជាអ្នកធានាឲ្យគាត់?; មានសំបុត្រធានាឬទេ?*

**ធានី** *ន.* (សំ. បា.) នគរ, ក្រុង; ខេត្ត, ស្រុក; ច្រើនប្រើជា *រាជធានី* ក្រុងដែលមានព្រះរាជាគង់នៅជាប្រធាន ។ បើប្រទេសដែលឥតព្រះរាជាគ្រប់គ្រងនគរ ហៅថា *រដ្ឋធានី* ។ ពាក្យនេះជាវេវចនៈនឹងពាក្យ *ឋានីយ* (ម. ព. នោះផង) ។

**ធារ** *ន.* (សំ. បា. *ធារ* "ទ, សំណុំ, ដំណើរហូរចុះ") ជំនន់ស្រូវ, អង្ករឬគ្រាប់ធញ្ញជាតិដែលបាក់បង្ហូរទុក : *ធារស្រូវ, ធារទឹក; ចាក់ធារ* ។ ការទ្រទ្រង់, ទប់ទល់, ធន់ទ្រាំ, បិទបាំង : *មើលទៅប្រហែលជាមិនធារទេដឹង* (ត. សា.) ។

**ធិ** *កិ.* (សំ. "ទ្រទ្រង់, កាន់កាប់; ធ្វើឲ្យសម្រេច...") ប្រឡូង, ប្រណាំងគ្នា : *ធិបណោរ* (ត. សា.) ។

**ធីតា** (ធីតា) *ន.* (បា. *ធីតុ > ធីតា*; សំ. *ទុហិតា*) កូនស្រី : *ធីតាខ្ញុំមានក្បាលរៀនណាស់* ។

**ធិប** *កិ.* (ឃ.) បំបាត់ចោល, លើកចុះពីសមចោល, លើកទុកមួយអន្លើ : *សត្វិការបៀនេះធិបចោលទៅកុំទុក; រឿងនេះធិបទុកមួយអន្លើសិន កុំតាលលើកយកមកនិយាយ* (ត. សា.) ។

**ធឹង** *ឬ.* ពាក្យសម្រាប់និយាយផ្សំនឹងពាក្យ *ធឹង* : *ធឹងធឹង* ដែលមានឫកពារឡេមមិនធ្ងន់ ។

**ធី** *ន.* (ឃ.) បែប, យ៉ាង, មុខ : *មួយធី, ពីរធី; ធីល្អ, ធីអាក្រក់, របស់នេះមានប៉ុន្មានធី?*

**ធុង ១** *ន.* ល្អឬគ្រួសសម្រាប់ដងទឹក, ដាក់ទឹក, ដាក់វត្ថុផ្សេងៗ ឬដាក់វត្ថុដែលជាផង់ ។

**ធុង ២** *ន.* ឈ្មោះនាគមួយប្រភេទ មានសូរឮធ្ងន់

រណ្ដំ : រនាតធុង ។

**ធុញ** កិ. (សំ. ធុញ្ញ ឬ ធូញ្ញ "ញ័រ, ចំប្រប់, លះបង់...") ចង្អល់ក្នុងចិត្ត, ក្រាញ់ចិត្ត, ជិនឆ្អន់, ធ្មើយណាយ ណាយនឹង : ខំប្រឹងរៀនទៅ កុំធុញៗ ធុញថប់ ធុញនិង ថប់បារម្ភផង ។ ធុញទ្រាន់ ធុញផងទ្រាន់ឬក្រាញ់ចិត្តផង ។

**ធុតង្គ ឬ ធូតង្គ** (ធុត-តង់ ឬ ធូត-តង់) ន. (សំ. បា.) អង្គរបស់ខត់ជាគ្រឿងកម្ចាត់នូវកិលេស ។ ពាក្យនេះជាឈ្មោះវត្ត ប្រតិបត្តិដោយឡែក សម្រាប់បព្វជិតក្នុងព្រះពុទ្ធសាសនាកាន់តាម កម្លាំងសទ្ធា ដើម្បីកម្ចាត់បង់គ្រឿងសៅហ្មងចិត្តឲ្យចុះ ។

**ធុន** ន. គ្រឿងទំងន់មួយដែលមានបែបយ៉ាងនិងកំណត់តាម- ខ្លួនគ្នា : តានមួយធុន, កៃមួយធុន ។

**ធុរៈ** ន. (សំ. បា. ធុរ) រវល់, ដំណើរធ្លាក់ដោយកិច្ច នីមួយ : ខ្ញុំទៅកុំបានដោយមានធុរៈ ។

**ធុរនិក្ខេប** (ធុរៈ-និក-ខេបៈ ឬ —ខេប) ន. (បា.; សំ. ធុរនិក្ខេប) ការដាក់ធុរៈ, ការលែងរវល់ ។

**ធូតង្គ** (ម. ក. ធុតង្គ) ។

**ធូប** ន. (សំ. បា.) គ្រឿងក្រអូបធ្វើដោយលម្អិតសំបក ឈើ, ខ្លឹមឈើឬជ័រឈើមានក្លិនក្រអូបប្រហើរ, សព្វសួនដោយ បន្តោះជាស្លួលឬជាដុលក៏មានខ្លះ សម្រាប់អុជបង្ហុយផ្សែងជា គ្រឿងបូជា (ជាធូបធ្លាក់ផងទៀត) ។

**ធូមកាលិក** (ធូម-កាលិក) គុ. ឬ ន. (បា.) ដែល ប្រព្រឹត្តទៅឬដែលឋិតនៅ, ដែលមានត្រឹមតែផ្សែងភ្លើងប៉ុណ្ណោះ ធាតុត្រឹមតែផ្សែងភ្លើង, មានអត្ថន័យថា ធាតុល្អរបស់គ្រូរបស់ មាតាបិតាកាលបើនៅលោយសព្ទអ្នកមានគុណទាំងនោះរួចហើយ, ក្រោយពីនោះមក ធាតុល្អនោះក៏គង់ ហាក់ដូចជាហើរចាត់ទៅ ជាមួយនឹងផ្សែងភ្លើង គឺព្រោះសិស្សនិងបុត្រធីតាទាំងឡាយ គុំ ប្រតិបត្តិតាម : សិស្សគណនិងបុត្រធីតាទាំងឡាយ គួរកុំញុំាងធាតុល្អរបស់គ្រូនិងមាតាបិតាទាំងឡាយ ឲ្យជាធូមកាលិកឡើយ ។

**ធូមកេតុ** (ធូម-កេត) ន. (សំ. បា.) ផ្កាយដុះកន្ទុយ ។

**ធូរ** គុ. ទំនេរពីតឹង តឹងណាយ, រលុង ។ កិ. ស្រាក, ស្បើយ (ជំងឺ) : ជំងឺជាតខ្ញុំ ថ្ងៃនេះបានធូរបន្តិច ។

**ធូលី** ន. (បា. ធូលិ) ដី, លម្អង, ល្អង (មាន លម្អងដីជាដើម) : មើលទៅឃើញធូលីហុយក្រោធ ។

**ធួ** (ម. ក. ធូ) ។

**ធួន** (ម. ក. ធូន) ។

**ធៀប** កិ. ផ្ទឹមរបស់ច្រើនមុខដាក់មើលឲ្យដឹងជាខាងណា ល្អ-អាក្រក់ឬខាងណាតិច-ច្រើនជាងគ្នា ជាដើម : ធៀបគ្នា មើលទៅ ឃើញថារបស់អ្នកគ្រាន់បើជាងរបស់ខ្ញុំ ។ ប្រើជាមួយនឹងពាក្យ ប្រៀប ក៏មាន : ប្រៀបធៀប គឺ ប្រដូចដោយធៀបគ្នាមើល ។



**ធេង** គុ. ដែលធ្លាយរលោះ, ទទេរលោះ, រលោះស្ងួត : ពោធិ៍ធេង, ស្ពានធេង ។ ល្ងីល្ងើ, រួសរាយព្រៃពេក (ប្រើជាមួយនឹងពាក្យ ធំ) : ផ្ទះធំធេង, សមុទ្រធំធេង ។

**ធេងធោង** កិ. វិ. ឬ គុ. ឃ្លេងឃ្លោង, ស្រាលខ្លួន មិនមាំខ្លួនដោយជាយកម្លាំង : ដើរធេងធោង; ដំណើរ ធេងធោង ។

**ធោរក:** (—រ:—) ន. (បា. ធោរក) អ្នកបោក គក់លាងជម្រះសម្អាតគ្រឿងសម្លៀកបំពាក់ជាដើម (បើស្ត្រីជា ធោរិកា) ។

**ធោវនដ្ឋាន** (—វ:ន័ត-ឋាន) ន. (បា.) ទីកន្លែង សម្រាប់លាងជម្រះសម្អាតនូវសម្លៀកបំពាក់, កំពង់ទឹកសម្រាប់ បោកគក់ជាដើម ។

**ធុំ** កិ. បាច់ក្លិន, ធំក្លិនដោយប្រមុះ : ធុំក្លិនក្រអូប, ធុំក្លិនស្អុយ ។

**ធំ ១** គុ. ទំហំពីតូច គឺមានរូបមានសំណុំសំនួនច្រើនជាង គេ ។ ធំធាត់ ឬ ធាត់ធំ ដែលធំនិងធាត់ផង ។ (ត. ប្រ.) ដែលកាន់តែធំឡើងៗកាលកលុងក្នុងកាយសម្បាប់កាលឡើង : ជំងឺនេះ កាន់តែធំធាត់ក្រៃលែងហើយ ។

**ធំ ២** ប. ស. ពាក្យសម្រាប់ក្មួយហៅបងប្រុសឬបងស្រី របស់បិតាឬរបស់មាតា ក្នុងទីចំពោះមុខឬកំបាំងក៏ហៅបាន : អញ្ជើញធំអង្គុយ; ពាក្យចំនើង ធំ; បើក្នុងទីកំបាំង ច្រើនហៅថា ឪពុកធំ គឺធំប្រុស, ម្ដាយធំ គឺធំស្រី; អ្នកដែល មិនមែនជាញាតិ ដែលមានអាយុច្រើនស្រករនឹងឪពុកធំឬម្ដាយធំ ក៏ហៅ ធំ ឬ អ៊ំ បានដែរ ។

**ធ្ងន់** គុ. ទំនងពីស្រាល គឺមានទម្ងន់ : អង្ករមួយបាវ នេះធ្ងន់ណាស់ ខ្ញុំលីមិនរួចទេ ។ ក្រៀល, ជាប់ម៉ាំ : ជំងឺធ្ងន់, ទោសធ្ងន់ ។ ល្អ, ក្រាស់សម្បុល : ស្រូវធ្ងន់ គឺស្រូវដែលធ្វើយូរទៅទើបបានផ្លែ ។ ព. ផ្ទ. ស្រូវស្រាល ។ ចង់, ស្ដាប់មិនស្ទើរ : ធ្ងន់ត្រចៀក ។ មានអំណត់, ដែល ស៊ូទ្រាំអត់ធ្មត់ មិនងាយនឹងប្រែប្រួលតាមផ្លាស់ : មនុស្ស នេះ មានចិត្តធ្ងន់ណាស់ ។ ល ។

**ធ្ងន់ធ្ងរ** គុ. ដែលមានចិត្តធ្ងន់, ដែលចេះអត់ចេះទ្រាំ, មានអំណត់, ប៉ុនអត់ប៉ុនទ្រាំ : ចិត្តធ្ងន់ធ្ងរ, មនុស្សធ្ងន់ធ្ងរ (និយាយចំពោះតែចិត្ត, អត្ថាស្រ័យប៉ុណ្ណោះ ព្រោះពាក្យ ដែលផ្សំជាមួយនឹង ធ្ងន់ នេះមានច្រើន ត្រូវរកមើលនៅ ដំណើរសេចក្ដី) ។ ម. ព. ធ្ងន់ ទៀតផង ។

**ធ្ងាង** គុ. ប្រឡង : ក្បាលធំធ្ងាង ។

**ធ្ងើង** គុ. ឬ កិ. វិ. ទើងទើង, ឆ្ងើង : ដើរចេញធ្ងើង មកពីគុម្ពព្រៃ ។

**ធ្នើល** កុ. ប្រហែល, ទំនងដែល ។

**ធ្នោង** កុ. ឬ កិ. វិ. ប្រវែង, ខ្ពង, ខ្ពាល, ខ្ពោល : *លេចធ្នោង, ងើបធ្នោង* ។

**ធ្នោល** កិ. វិ. (ដូចគ្នានឹង *ធ្នោង* នឹង *ខ្ពោល* ដែរ)។

**ធ្នាំង** កុ. ឬ កិ. វិ. ខ្ពាំង, ឆ្នាំង (ព. ក.) ។

**ធ្នង់** ន. ឈ្មោះឈើតូចក្រញូង ទំហំប្រហែល មានផ្លែប្រហើរ សាច់ជាប់ស្អិតជាប់ក្រញូង ។

**ធ្នល់** ន. ឈ្មោះពួកយ៉ាងធំ : *ក្អមធ្នល់, ឆ្នុកទឹក អស់ប្រាំធ្នល់* (ហៅតាមទម្លាប់ស្រុក) ។

**ធ្នស់** ន. គ្រឿងទល់ក៏ធ្វើដោយឫស្សី, ដោយមែកឈើជាដើម សម្រាប់ទល់ទាំងត្រីមិនឲ្យធ្លុះឡើងច្រើនផ្លូវ ឲ្យធ្លុះឡើងតែតាមផ្លូវដែលបើក ដើម្បីឲ្យតម្រង់ទៅត្រូវត្រង់ប្រដាប់នេសាទ : *ទល់ធ្នស់, ធ្វើធ្នស់, ដាក់ធ្នស់* ។

**ធ្នាក់** ន. សត្វដែលជាមេដាក់ និសត្វសម្រាប់ដាក់, សម្រាប់ឲ្យតែងយកល្បើយ, យកបាស : *មាន់ធ្នាក់, ទាធ្នាក់, ម័រធ្នាក់* ។ ព. ប្រ. ជា អ្នកបោកអន្ទង, អ្នកនាំគាំ ។

**ធ្នាប់** ន. ក្តាស់ប្រវែងទទឹងប្រមាណ២ធ្នាប់ដៃ : *បណ្ដាយប្រាំធ្នាប់, ទទឹងបីធ្នាប់* ។

**ធ្នារ** ន. ផ្លូវទឹកសាលាគារណៈដែលមានផ្លូវផុតទៅមកមិនដាច់ : *ផ្លូវទឹកធ្នារទៅលើអ្នកផង* ។ ធ្នារទឹក, ធ្នារខ្យល់ : *ធ្នារទឹក, ធ្នារខ្យល់* ។

**ធ្នឹម** ន. គ្រឿងប្រដាប់កាយ : *ធ្នឹមសម្ពត់ស្រា* ។

**ធ្នឹម** ន. ឈ្មោះគ្រឿងគេហដ្ឋានជាមេផ្ទឹមសសរទ្រដឹងតក ឬទោះតែជើងតក៏អាចប្រើបាន ។

**ធ្នឹមបណ្ដោត** ន. ធ្នឹមដែលតាបភ្ជាប់នឹងក្លោងទ្រដឹងតក ជាធ្នឹមមេគេហដ្ឋានទាំងប៉ុន្មាន ។

**ធ្នូ** ន. (បា. ធនុ; សំ. ធនុ ឬ ធនុស) អាវុធធ្វើដោយ...បី, ឫស្សី ឬលាងក្រាំង មានដងហេតបត្តោះសម្រាប់បាញ់ដោយព្រួញ ។ ឈ្មោះរាសីទី៩ តាមសុរិយគតិ ដោយរាប់រាសីមេសជារាសីទី ១, បើរាប់រាសីមករ ជារាសីទី ១ រាសីធ្នូជារាសីទី១២, សព្វថ្ងៃនេះប្រើជារាសីទី ១២ តាមសុរិយនិយម ។

**ធ្នូឡែក** ន. ឈ្មោះធ្នូមួយប្រភេទសម្រាប់បាញ់នឹងគ្រាប់ មានគ្រាប់ដែលបាញ់ពាលឲ្យស្ទួនឬដុំឲ្យធ្លិនជាដើម ។

**ធ្នើ** ន. ថ្នាក់ខ្ពស់សម្រាប់ទុកវត្ថុផ្សេងៗ : *ដាក់ការខ្សែលើធ្នើ, ទៅលើធ្នើ* ។

**ធ្នះ** ន. ទីស្រប់នៅលើមែក, លើប្រាសាទឈើ ឬមានសសរធ្វើកណ្ដាលភល, ធ្វើក្នុងព្រៃឬក្នុងទឹកសម្រាប់ឡាក់ខ្លួនពួនចាំចាប់ចាំប្រហារសត្វឬត្រី ។

**ធ្នង់** កុ. ខ្វាំង, ខ្ពង់ មិនស្មើស្មីនិយាយ (តាមឧត្តតិកកើតមក) : *មនុស្សធ្នង់* ។



**ធ្មត់** ឧ. ពាក្យសម្រាប់និយាយផ្ទួននឹងពាក្យ *អត់* : *អត់ធ្មត់* ទំព្រាំតស៊ូឲ្យតែប្រញាប់ប្រា ក្នុងស្របាក់មួយ ។

**ធ្មប់** ន. ឈ្មោះមន្តអាថ៌ពិសមួយប្រភេទ ជាគ្នានឹងរាប : *គ្រូធ្មប់, មេធ្មប់* (ជាចំណេះអាក្រក់ព្រៃ ហៅថា *ទុព្ភិជ្ជា* ឬ *ទុព្ភិជ្ជា; សំ. ទុវ៌ិទ្យា* ) ។

**ធ្មា** ន. ឈ្មោះឈើមួយប្រភេទមានខ្ទឹមរឹង, ប្រយទំប្រើជាអន្ទាក់បាន ជាឈើមានបញ្ញា ។

**ធ្មឹង** កិ. វិ. នៅស្ងៀមមិនស្ទើ, ប្រទឹង : *អង្គុយធ្មឹង, ឈរធ្មឹង* ។

**ធ្មុង** ន. អវយវៈស្រួចមុតមានពិសសម្រាប់ការពារខ្លួនរបស់ត្រីពួកខ្លះ : *ធ្មុងត្រីអណ្ដែង, ធ្មុងត្រីកញ្ចុះ* ។ ព. ប្រ. *កាចធ្មុង* សះបង់ពោលនូវចិត្តកាលកំណាចកាចសាហាវ ។

**ធ្មុងកញ្ចុះ** ន. ឈ្មោះឈើរោមមួយប្រភេទ មានបន្លាស្រដៀងនឹងធ្មុងត្រីកញ្ចុះ ។

**ធ្មើង** កុ. ឬ កិ. វិ. ធ្មឹង, ទំងទឹង ។

**ធ្មេច** កិ. បិទត្របកភ្នែក ។ ព. ប្រ. *ធ្មេចភ្នែក* កិ. ឃើញធ្វើជាមិនឃើញដោយមិនយកចិត្តទុកដាក់... ។ *តាំងធ្មេច* ឬ *តាំងធ្មេចភ្នែក* កិ. វិ. តាំងពាស់ឬដោយល្ងង់មិនយល់ : *ធ្វើការតាំងធ្មេចភ្នែក, ស៊ីតាំងធ្មេចភ្នែក* ។ *មនុស្សធ្មេចភ្នែក* កុ. មនុស្សដែលមិនយកចិត្តទុកដាក់នឹងកិច្ចការទាំងពួង ឬមនុស្សដែលល្ងង់ស្លូតស្លឹង ។ *ចុះហត្ថលេខាធ្មេចភ្នែក* ឬ *ចុះហត្ថលេខាខ្វាក់* ចុះហត្ថលេខាដោយមិនបានមើលសេចក្តីក្នុងលិខិតនោះសោះ ឬចុះហត្ថលេខាលើក្រដាសលាតឥតមានអក្សរ (ដោយគេបញ្ឆោត) ។

**ធ្មេញ** ន. អាការៈក្នុងមាត់ សម្រាប់ទំពា ។

**ធ្មេញកណ្ដុរ** ន. ឈ្មោះគ្រឿងសញ្ញាពុម្ពិមួយប្រភេទ ( ៉ ) សម្រាប់សម្លាប់សំឡេងអក្សរ ៩ តួគឺ ង, ញ, ន, ម, យ, រ, ល, វ បំផ្លាស់សំឡេងខុសពីសំឡេងប្រក្រតី គឺ ង៉, ញ៉, ន៉, ប៉, ម៉, យ៉, រ៉, ល៉, វ៉; ប៉ុន្តែបើមានស្រៈ ឬនិគ្គហិតនៅពីលើ ត្រូវយកធ្មេញកណ្ដុរមកដាក់ខាងក្រោមវិញ ដូចយ៉ាង *ង៊ីកង៉ក់, ញ៉ាំញ៉ី, ប៊ុនប៉ោ* ជាដើម (ម. ព. *មូសិកទន្ត* ផង) ។

**ធ្មេញកណ្ដាប** ន. ឈ្មោះគ្រឿងឧបក្រណ៍មួយប្រភេទ សម្រាប់ចាក់បញ្ចូលសរសៃអន្ទងក្នុងធ្មេញឈើ ។

**ធ្មេញក្របី** ន. ឈ្មោះល្បាក់រជតាបែបមួយ មានរាងសណ្ឋានស្រដៀងនឹងធ្មេញក្របី ។

**ធ្មេញចាស់** ន. ផ្កាប់ឈើមានល្បាសសម្រាប់ចាប់ភ្ជាប់ស្លឹ, ការឿ ជាដើម ។

**ធ្មេញឈើ** ន. ប្រទាសធ្វើដោយចាន្ទោះល្អិតជាគ្រឿងឧបករណ៍ សម្រាប់បញ្ចូលសរសៃអន្ទង, សម្រាប់កាសបញ្ចូលចាក់ឧបាយ ។

**ធ្មេញត្រី** ន. ឈ្មោះឈើតូចមួយប្រភេទច្រើនដុះនៅទំនាបមានមាត់បឹង, មាត់ត្រពាំងជាដើម : *ដើមធ្មេញត្រី* ។

**ធ្មេញសេះ** ន. ឈ្មោះថ្មមួយប្រភេទ មានសាច់រឹងស្រួយ : *ថ្មធ្មេញសេះ* ។

**ធ្មៃ** ន. ឈ្មោះវល្លិជាតិឈ្លូកព្រៃ សំបកប្រើធ្វើខ្សែជាប់បានយូរ : *ខ្សែធ្មៃប្រើជាប់បានយូរ* ។

**ធ្មោង** គុ. ឬ កិ. វិ. ធ្លោង, គោងគោង ។

**ធ្មៅ** ឬ **ខ្មៅ** ន. ឈ្មោះប្រទាលមួយប្រភេទតូចទាល់, មើមស្មោរពើកោគជាន (ហៅតាមទម្លាប់ស្រុក, អ្នកស្រុកខ្លះហៅ *ខ្មៅ*, ខ្លះហៅ *ធ្មៅ*) ។

**ធ្មាំង** កិ. វិ. ដែលកាងសំកាំងស្លឹកត្រចៀក ដើម្បីតាំងស្ដាប់ឲ្យជាក់ (សត្វ) : *សេះទ្រស្លឹកត្រចៀកធ្មាំង* ។

**ធ្យាន** (ម. ព. *ឈាន* ន.) ។ ពាក្យនេះខ្មែរយើងប្រើជា កិ. កំមាន : *ធ្យានទៅ* គឺទៅដោយអំណាចឈានៈ *ហោះធ្យាន* សំដៅសេចក្ដីថាទៅតាមអាកាសជាប្រឹថពីដោយអំណាចឫទ្ធិនៃឈាន ។ តាមសេចក្ដីពិត, លោកដែលបានសម្រេចឈានមិនមែនហោះទេ, គឺបើត្រូវការចង់ទៅតាមអាកាស លោកចូលឈានដោយ *បឋវីកសិណ* គឺយកដីធ្វើជាអារម្មណ៍ តាំងអធិដ្ឋានអាកាសត្រង់ផ្លូវដែលត្រូវការទៅនោះ ឲ្យកើតជាដី ហើយលោកដើរតាមផ្លូវទៅដូចគេដើរលើដីធម្មតា, គ្រាន់តែកាច់រហ័សឆាប់រហ័សរួចជាងដំណើរជាប្រក្រតីប៉ុណ្ណោះ បើត្រូវការចង់ទៅក្នុងដី លោកចូលឈានដោយ *អាបោកសិណ* គឺយកទឹកធ្វើជាអារម្មណ៍ តាំងអធិដ្ឋានដីត្រង់ផ្លូវដែលត្រូវការទៅនោះឲ្យលាយក្លាយជាទឹកហើយចូលផ្លូវនោះ ; *តេជោកសិណ* គឺយកទឹករស់ធ្វើជាអារម្មណ៍ អធិដ្ឋានឲ្យមានទឹករំលងបកដកក្លែកទឹកឲ្យប្រភេទក្នុងទៅជាផ្លូវដើរបាន; និយាយដោយខ្លីថា លោកប្រើឈានបង្កើតតាមតែចំណង់ ផ្លាស់ប្ដូរធាតុតាមត្រូវការ ប៉ុណ្ណោះឯង; តែប្រើនិយាយតាមទម្លាប់ថា *លោកហោះ, លោកផ្លែកដី, ផ្លែកទឹក, ដើរលើទឹក* ។ល។

**ធ្យានចិត្ត** (ឈានៈចិត) ន. (ម. ព. *ឈានចិត្ត*) ។

**ធ្យានផល** (ឈានៈផល់) ន. (ម. ព. *ឈានផល*) ។

**ធ្យានពល** (ឈានៈពល់) ន. (ម. ព. *ឈានពល*) ។

**ធ្យានសុខ** (ឈានៈសុក) ន. (ម. ព. *ឈានសុខ*) ។

**ធ្យានឫទ្ធិ** (ឈានៈរឹត) ន. (ម. ព. *ឈានឫទ្ធិ*) ។

**ធ្យានានុភាព** (–ភាប) ន. (ម. ព. *ឈានានុភាព*) ។

**ធ្យូង** ន. សំណល់ភ្លើងឆេះ សំណល់កម្ទេចនៃឧសឬឈើជាដើម មានពណ៌ខ្មៅ ដែលមិនទាន់ឆេះសុសរួចទៅជាផេះ : *ធ្យូងឈើ, ធ្យូងឫស្សី, ធ្យូងថ្ម* ។ មន្ទិលខ្មៅដែលកកជិតជាប់ក្រាស់នៅគូទឆ្នាំង ក៏ហៅថា *ធ្យូង* ដែរ : *ធ្យូងឆ្នាំងបាយ* ។



**ធ្លក** ន. ឈ្មោះឈើមួយប្រភេទតូចចំបក់ ផ្លែទុំសាច់ពណ៌ស្រទៀតនឹងក្រមួនអង់ ក្លិនក្រអូបល្ហាន់ មានម្សៅក្រាស់ជិតក្រឡៃ ។

**ធ្លា** ន. ផ្លូវធំដែលបររទេះបាន : *ផ្លូវធ្លា, ដើរតាមធ្លា* ។ ទីលានធំទូលាយ : *ធ្លាមុខផ្ទះ* ។

**ធ្លាក់** កិ. របូតពីលើជ្រុះចុះមកក្រោម : *ធ្លាក់អំពីលើកន្សហាល* ។ របូតមាត់ចេញសំដីប្រាប់ការណ៍ពិត : *ស្ដីលេងបណ្ដាលតែធ្លាក់សំដីពិត* ។ *ធ្លាក់ខ្លួន* ចុះស័ក្តិឬទ្រព្យសម្បត្តិ ។ល។

**ធ្លាប់** កិ. តែង, តែងតែ, រមែង, ដែលមានទម្លាប់ : *ស្រុកនុះខ្ញុំធ្លាប់ទៅហើយ, ការនុះខ្ញុំធ្លាប់ធ្វើហើយ ; លួចគេធ្លាប់ដៃ ដេកថ្ងៃធ្លាប់ភ្នែក* ។ *ធ្លាប់តែបានសុខស្រួល* តែងតែបានសុខស្រួល ។ *ធ្លាប់តែនិយាយត្រង់* តែងតែនិយាយត្រង់ ។ល។

**ធ្លាយ** ១ កិ. រហែក, ធ្លុះ, របើក ដោយមានកម្លាំងទាំងឬមានទម្ងន់មកពីគប៉ះប្រាន : *ទូកធ្លាយ, ទំនប់ធ្លាយ, បូសធ្លាយ* ។ បះញញើតជាប្រាប់រឿងពិតបាំង : *ខ្ញុំសួរពុះចំលើរឿងហ្នឹងទៅ ស្រាប់តែគាត់ធ្លាយប្រាប់គ្រប់ៗ អស់គ្មានសល់* ។ល។

**ធ្លាយ** ២ ន. ចង្កោមផ្លែដូង, ផ្លែត្នោត, ទន្សែជាដើម : *ដូងមួយធ្លាយ, ត្នោតមួយធ្លាយ* ។

**ធ្លឹង** កិ. បង្ហូបពើងទាំង ២ ដោយទទឹង : *ធ្លឹងដៃ* ។

**ធ្លុង** ១ ន. ខ្សែរលាក់ដែលក្រចៀបឬខ្លាញ់ : *វេញបញ្ចូលធ្លុង, ខ្សែកធ្លុង, ខ្សែបធ្លុង,* ។ ព. ប្រ. *ធ្លុងមួយ ឬ ក្រធ្លុងតូច* ទំរួបគំនិតគ្នា, វេញគំនិតចូលគ្នាដូចគេវេញខ្សែបញ្ចូលធ្លុង ។

**ធ្លុង** ២ ឬ **ធ្លូង** គុ. ឬ កិ. វិ. ដែលប្រហោងតែមានតួរើស : *ធ្លាប្រហោងធ្លុង; មើលទៅឃើញធ្លុង* ។

**ធ្លុញ** (ម. ព. *ធ្លុញ* ១ កិ.) ។

**ធ្លុះ** គុ. ដែលមានប្រហោងរហូតទៅម្ខាង : *ភ្លុមធ្លុះ* ។ ព. ប្រ. ប្រើជា កិ. ឬ កិ. វិ. *ក្រឡេកធ្លុះ* ទីក្រឡេកឃើញភ្លេត, ឃើញសេចក្ដីកំបាំងច្បាស់ប្រាកដ ។ *ចាក់ធ្លុះ* គឺគ្រាស់ដឹង ។ *ធ្លុះធ្លាយ* ធ្លុះត្រាតែឆ្ងាយ ។ ព. ប្រ. ចេះឬយល់ឥតទើសទាល់ : *ចេះធ្លុះធ្លាយ, យល់ធ្លុះធ្លាយ* ។ *ក្រឡេកឃើញធ្លុះ* ឃើញច្បាស់ឥតកំបាំង ។ល។

**ធ្លូ** គុ. ដែលមើលទៅឃើញស្រួល : *ត្រង់ធ្លូ* គឺត្រង់ស្រលួតស្រឡះ ។

**ធ្លុញ** ១ កិ. ត្រដូតខ្សែ, ហាត់ខ្សែ (ប្រើតាមទម្លាប់ដោយស្រុក), អ្នកស្រុកខ្លះហៅ *ធ្លុញ* ។

**ធ្មុញ ២ ឬ ធ្មុញ** *កុ. ឬ កិ. វិ.* ពាក្យសម្រាប់ចំរើនពាក្យខុស, ពាក្យឃ្លាតឲ្យប្រាកដ : *ខុសធ្មុញ ឬ ខុសធ្មុញ* គឺខុសទទេសោះ ឥតប្រកែកបានឡើយ ។

**ធ្មួង** *កុ. ឬ កិ. វិ.* ដែលប្រហាក់ប្រហែលឥតមានគ្រឹះទើស : *ខ្វាក់ប្រហធ្មួង, មើលទៅឃើញធ្មួង* (ម. ព. ធ្មួង ២ ឬ ធ្មួង កុ. ឬ កិ. វិ. ទៀតផង) ។

**ធ្មែរ ឬ ធ្មែល** *កុ. ឬ កិ. វិ.* ពាក្យសម្រាប់ចំរើនពាក្យសៀងឲ្យឃើញជាក់ស្តែង : *សៀងធ្មែរ* គឺសៀងខ្លាំង (ម. ព. *ធ្មែ* ផង) ។

**ធ្មោ** *កិ. វិ.* សៀងទៅមុខឬទៅលើ ដូចគេលោតខ្លួនទៅដោយជាក់ច្បាស់ : *លោតធ្មោ, គោមហោះឡើងធ្មោ* ។

**ធ្មោយ** *កិ.* ធ្វេស, ប្រហែស, ភ្លាំងភ្លាត់ស្មារតី, ភ្លាំងភ្លាត់គំនិត : *ធ្មោយគំនិត* ។

**ធ្មាំង** *កិ. វិ.* ពាក្យសម្រាប់ចំរើនពាក្យ ស្រាត, ពាក្យលែងខ្លួនឲ្យជាក់ស្តែង : *ស្រាតធ្មាំង* គឺស្រាតទាំងស្រុង (ប្រើតែចំពោះលយចំពោះតែខ្លួនប្រុសខ្លួន) ។ *លែងខ្លួនធ្មាំង* គឺលែងខ្លួនមានតែសម្លៀក ។

**ធ្វះ** *ន.* ទឹកប្រលាក់មានព័ណ៌ទៀប ធ្វើឲ្យស្នាមលាយគឺតែងទឹកជាក់កំបោរស : *សំពត់ប្រលាក់ធ្វះ, ព័ណ៌ធ្វះ* ។

**ធ្វើ** *កិ.* សម្រេចអំពើ គឺសម្រេចកិច្ចការផ្សេងៗ : *ធ្វើបុណ្យ, ធ្វើស្រែ, ធ្វើការ* ។ កិរិយាសព្ទ *ធ្វើ* នេះសម្រាប់ប្រើផ្សំជាមួយនឹងសព្ទដទៃបានច្រើនជាអនេកតាមគួរដល់ការប្រើ, ដូចជា : *ធ្វើជាមិនស្គាល់, ធ្វើជាមិនឃើញ* ជាដើម ។

**ធ្វើទុក្ខ** *កិ.* ធ្វើឲ្យលំបាក, ធ្វើឲ្យបៀតបៀនដល់ចិត្ត, ធ្វើឲ្យមានកង្វល់ : *យប់មិញ ខ្ញុំឥតបានដេកមួយស្រាវទេ ព្រោះកូនតូចវាធ្វើទុក្ខខ្លាំងពេក* ។ *ធ្វើទុក្ខបុកម្នេញ* ធ្វើទុក្ខពុកឲ្យព្រួយម្នេញជានិច្ច ។

**ធ្វេស** *កិ.* ធ្មោយ, ប្រហែស : *ធ្វេសស្មារតី, ធ្វេសគំនិត* ។

**ធ្វេសធ្វេ ឬ ធ្វេធ្វេស** *កិ.* ធ្វេសពីរដង គឺធ្វេសហើយធ្វេសទៀតដល់ពីរដង ឬធ្វេសច្រើនដង ។ ប្រើតែក្នុងកាព្យ, ដូចជា : *ខ្លួនប្រុសប្រយ័ត្នកុំបីធ្វេស បើបានជាធ្វេសកុំធ្វេសធ្វេ ធ្វេធ្វេសប្រហែសឃើញច្រើនកែ វិនាសទ្រព្យគងពុំសូវមាន* ។